ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៤ អយក.សប្រ៣

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការផ្សព្វផ្សាយជាផ្លូវការរបាយការណ៍ថ្នាក់តំបន់ នៃវង្វាយតម្លៃលទ្ធផលសិក្សាកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ (SEA-PLM 2024)

ក្រសួងអប់រំ យុវជន និងកីឡាសូមជម្រាបសាធារណជនទាំងអស់មេត្តាជ្រាបថា៖ លេខាធិការដ្ឋាន SEAMEO បានប្រារព្ធពិធីផ្សព្វផ្សាយជាផ្លូវការនូវរបាយការណ៍ថ្នាក់តំបន់ នៃវង្វាយតម្លៃលទ្ធផលសិក្សាកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ (SEA-PLM 2024) នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ នាទីក្រុងម៉ានីល ប្រទេសហ្វីលីពីន។

ប្រទេសកម្ពុជាបានចូលរួមអនុវត្តវង្វាយតម្លៃថ្នាក់តំបន់ SEA-PLM លើកទី១ នៅឆ្នាំ២០១៩ និងលើកទី២ នៅឆ្នាំ២០២៤ ជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ លទ្ធផលសំខាន់ៗរបស់កម្ពុជាក្នុងរបាយការណ៍ថ្នាក់តំបន់ SEA-PLM ឆ្នាំ ២០២៤ មានខ្លឹមសារដូចខាងក្រោម៖

សិស្សកម្ពុជាទទួលពិន្ទុជាមធ្យមផ្នែកអំណានកើនឡើង ៦ពិន្ទុ (២៩០ ក្នុងឆ្នាំ២០១៩ កើនដល់ ២៩៦ ក្នុងឆ្នាំ២០២៤) និងពិន្ទុជាមធ្យមផ្នែកគណិតវិទ្យាកើនឡើង ១២ពិន្ទុ (២៨៩ ក្នុងឆ្នាំ២០១៩ កើនដល់ ៣០១ ក្នុងឆ្នាំ២០២៤)។ អត្រាសិស្សដែលមានសមត្ថភាពអំណានកម្រិតខ្ពស់ (ពីកម្រិត ៥ ឡើងទៅ) បានកើនឡើងពី ២៧% ក្នុងឆ្នាំ២០១៩ ដល់ ៣៩% ក្នុងឆ្នាំ២០២៤។ ក្នុងចំណោមសិស្សទាំងនេះ អត្រាសិស្សឆ្នើមបានកើនឡើងពី ១១% ក្នុងឆ្នាំ២០១៩ ដល់១៨% ក្នុងឆ្នាំ២០២៤។ សិស្សឆ្នើមទាំងនេះកំពុងរៀននៅថ្នាក់ទី៥ ប៉ុណ្ណោះ ប៉ុន្តែពួកគេមានសមត្ថភាពធ្វើបានល្អប្រហាក់ប្រហែលនឹងសិស្ស ដែលនៅកម្រិតបញ្ចប់ការអប់រំនៅបឋមសិក្សា ក្នុងបណ្តាប្រទេសដទៃទៀត ដែលបានចូលរួមក្នុងវង្វាយតម្លៃ SEA-PLM។ អត្រាសិស្សដែលមិនអាចអានអត្ថបទងាយៗបានស្ទាត់ (ចាប់ពីកម្រិត ៣ ចុះក្រោម) បានថយចុះពី ៤៧% ក្នុងឆ្នាំ២០១៩ មកនៅត្រឹម ៣៧% ក្នុងឆ្នាំ២០២៤។ ចំណែកផ្នែកគណិតវិទ្យា អត្រាសិស្សដែលមានសមត្ថភាពខ្ពស់ (ពីកម្រិត ៥ ឡើងទៅ) បានកើនឡើងពី ៣៩% ក្នុងឆ្នាំ២០១៩ ដល់ ៦២% ក្នុងឆ្នាំ២០២៤។ ក្នុងចំណោមសិស្សទាំងនេះ អត្រាសិស្សឆ្នើមបានកើនឡើងពី១៩% នៅឆ្នាំ២០១៩ ដល់40% នៅឆ្នាំ២០២៤។ ទោះបីជាសិស្សឆ្នើមទាំងនេះកំពុងរៀននៅថ្នាក់ទី៥ ក៏ដោយ ក៏ពួកគាត់មានសមត្ថភាពធ្វើបានល្អប្រហាក់ប្រហែលនឹងសិស្ស ដែលនៅកម្រិតបញ្ចប់ការអប់រំនៅបឋមសិក្សា

អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

ក្នុងបណ្តាប្រទេសដទៃទៀតដែលបានចូលរួម។ អត្រាសិស្សដែលមានសមត្ថភាពទាប (ចាប់ពីកម្រិត ៣ ចុះក្រោម) បានថយចុះពី៣៦% ក្នុងឆ្នាំ២០១៩ មកនៅត្រឹម ២០% ក្នុងឆ្នាំ២០២៤។

ក្រសួងនឹងប្រកាសផ្សព្វផ្សាយ **«របាយការណ៍ថ្នាក់ជាតិនៃវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ (SEA-PLM 2024) របស់ប្រទេសកម្ពុជា»** នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម**សាធារណជន**ទទួលជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ២០២៥